ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ...៥៥.០២០...២០១៩ ស.ស.ណ

ថ្ងៃ ពុ ១០រោច ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែមីនា ឆ្នាំ២០២០

# សេចក្តីជូនដំណឹង
# ស្តីពី
# ការលើកទឹកចិត្តការប្រើប្រាស់សេវាអេឡិចត្រូនិក

ដើម្បីចូលរួមបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជម្ងឺកូវីដ១៩ ដែលកំពុងរីករាលដាល និងដើម្បីធានាសុវត្ថិភាព និងការពារហានិភ័យនានា ដែលអាចកើតមានឡើងជាយថាហេតុ ធនាគារជាតិនៃកម្ពុជា មានកិត្តិយសសូមលើកទឹកចិត្តដល់ការកាត់បន្ថយការប្រើប្រាស់/ចេញផ្សាយមូលប្បទានប័ត្រ សម្រាប់ធ្វើការជាត់ទាត់ និងទូទាត់ ជំនួសដោយការប្រើប្រាស់សេវាអេឡិចត្រូនិក តាមលទ្ធភាពដែលអាចធ្វើទៅបាន។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមគ្រប់ ក្រសួង-ស្ថាប័នពាក់ព័ន្ធ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទាំងអស់ និងសាធារណជន មេត្តាជ្រាប និងចូលរួមសហការ ចាប់តាំងពីថ្ងៃជូនដំណឹងនេះតទៅ។

**អគ្គនាយកបច្ចេកទេស**

**ជា សិរី**

ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧